**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**
លេខៈ ៣០៩ ......កប/ប្រ-ក

រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ [illegible] ឆ្នាំ២០០៧

# ប្រកាស
## ស្តីពី
## លក្ខខណ្ឌការងារ និងជីវភាពរស់នៅក្នុងសហគ្រាសឡឥដ្ឋ

## រដ្ឋមន្ត្រី ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការងារ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ ៥២ អនក្រ/បក ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- យោងតាមការចាំបាច់របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

## <u>សម្រេច</u>

**ប្រការ ១.-**

និយោជក នៃសហគ្រាស សិប្បកម្មឡឥដ្ឋទាំងអស់ ដែលស្ថិតក្នុងដែនអនុវត្តនៃមាត្រា១ នៃច្បាប់ស្តីពីការងារ ត្រូវ យកចិត្តទុកដាក់ដល់កម្មករនិយោជិតរបស់ខ្លួនទាំងអស់លើលក្ខខណ្ឌការងារឱ្យមានសុវត្ថិភាព និងជីវភាពរស់នៅ ដ៏សមរម្យ មានអនាម័យត្រឹមត្រូវ



អាសយដ្ឋានអគារលេខ ៣. មហាវិថីសហព័ន្ធរុស្ស៊ី. សង្កាត់ទឹកល្អក់២. ខ័ណ្ឌទួលគោក. ប្រអប់សំបុត្រ P.O Box 1506ទូរស័ព្ទ និង ទូរសារ: (០២៣) ៣៩៣ ៥៣៨

**ប្រការ ២.- សម្លៀកបំពាក់ការងារ**

និយោជក ត្រូវផ្តល់ឱ្យដោយឥតគិតថ្លៃ ដល់កម្មករនិយោជិតម្នាក់ៗ នូវសម្លៀកបំពាក់២សម្រាប់ ក្នុង១រដូវ/ឆ្នាំ។ សម្រាប់ទី១ ត្រូវផ្តល់ឱ្យនៅពេល១៥ថ្ងៃ ក្រោយពីកម្មករនិយោជិតនោះបានចូលធ្វើការដំបូង។ សម្លៀកបំពាក់ ១សម្រាប់ៗ ត្រូវមាន ២ផ្នែកយ៉ាងតិច គឺ សំពត់ឬខោ ហើយនិងអាវ ដែលមានទំហំស្របនិងខ្លួនប្រាណព្រមទាំង សកម្មភាពការងារ របស់កម្មករនិយោជិត។ និយោជក ត្រូវផ្តល់មធ្យោបាយសម្រាប់ថែទាំសម្លៀកបំពាក់ទាំងនោះ ដូចជាសាប៊ូជាដើម ។

បទបញ្ជាផ្ទៃក្នុង អាចកំណត់ពីលក្ខខណ្ឌដែលសម្លៀកបំពាក់នេះត្រូវបែងចែកប្រើប្រាស់ និងថែទាំ។

**ប្រការ ៣.- សម្ភារៈការពារបុគ្គល និងសម្ភារៈការងារ**

និយោជក ត្រូវផ្តល់ឱ្យដោយឥតគិតថ្លៃ ដល់កម្មករនិយោជិតម្នាក់ៗ នូវសម្ភារៈការពារបុគ្គលជាចាំបាច់ដូចជាស្បែក ជើង ស្រោមដៃ ឬមួកជាដើម។ល។

សម្ភារៈការងារដូចជា រទេះដឹកជញ្ជូនដីឬឥដ្ឋ ចប ពូថៅជាដើម ត្រូវមានសភាពមាំទាំ មិនបង្កឱ្យមានការលំបាកឬបង្កឱ្យមានគ្រោះថ្នាក់ដល់អ្នកប្រើប្រាស់ ឬអ្នកនៅជិតខាង។ ម៉ាស៊ីនកិនដីឥដ្ឋ ផលិតឥដ្ឋត្រូវរៀបចំយ៉ាងណាឱ្យមានសុវត្ថិភាព ដល់អ្នកធ្វើការ ដូចជាត្រូវមានបង្កាន់ដៃសម្រាប់តោងឬទប់កុំឱ្យរអិល គំរបម៉ាស៊ីនជាដើម។

មុននឹងអនុញ្ញាតឱ្យកម្មករនិយោជិតចូលទៅធ្វើក្នុងឡ ទោះនៅពេលជញ្ជូនឥដ្ឋចូលឬចេញក៏ដោយ និយោជកត្រូវ រកគ្រប់មធ្យោបាយធ្វើយ៉ាងណា ឱ្យឡមានសីតុណ្ហភាពធម្មតាសិន ( មិនឱ្យលើសពី៣៧អង្សាសេ)។

**ប្រការ ៤.- ការលើកដាក់ទម្ងន់ដោយកម្លាំងពលកម្ម-ការរៀបចំបង្គន់អនាម័យ-ការផ្តល់ភេសជ្ជៈអនាម័យ**

និយោជកនៃសហគ្រាស សិប្បកម្មឡឥដ្ឋទាំងអស់ ត្រូវអនុវត្តឱ្យបានត្រឹមត្រូវនូវប្រកាសៈ

- លេខ១២៤ ស.ក.ប.យ ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០០១ ស្តីពីការលើកដាក់ទម្ងន់ដោយកម្លាំងពលកម្ម
- លេខ០៥២ ស.ក.ប.យ ចុះថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០០១ ស្តីពីការរៀបចំបង្គន់អនាម័យ
- លេខ០៥៤ ស.ក.ប.យ ចុះថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០០១ ស្តីពីការផ្តល់ភេសជ្ជៈអនាម័យ ។

**ប្រការ ៥.- ទីតាំងរស់នៅសម្រាប់កម្មករនិយោជិតនិងគ្រួសារ**

ក្នុងករណីដែលកម្មករនិយោជិតមកស្នាក់នៅក្នុងសហគ្រាស សិប្បកម្មឡឥដ្ឋ ទោះដោយបុគ្គលខ្លួនម្នាក់ឯងឬជា គ្រួសារ ទាំងមូលក៏ដោយ និយោជកមានកាតព្វកិច្ចរៀបចំឱ្យមាន វាសនដ្ឋានសម្រាប់កម្មករនិយោជិតគ្មានគ្រួសារ នៅផ្សេង ហើយកម្មករនិយោជិតមានគ្រួសារនៅតាម គ្រួសារនីមួយៗដោយឡែក។ ការរៀបចំវាសនដ្ឋាននេះត្រូវធ្វើឱ្យស្របនឹងប្រកាស ស្តីពីវាសនដ្ឋានសម្រាប់កម្មករនិយោជិតរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ។ 148

**ប្រការ ៦.- ការងារសម្រាប់ស្ត្រី និងកុមារ**

កុមារអាយុក្រោម១៥ឆ្នាំ មិនអនុញ្ញាតឱ្យធ្វើការអ្វីទាំងអស់ក្នុងការដ្ឋានឡឥដ្ឋ ទោះដោយថាជាការជួយឪពុកម្តាយ ក៏ដោយ ។កុមារអាយុចាប់ពី១៥ឆ្នាំឡើងទៅ រហូតក្រោម១៨ឆ្នាំ ត្រូវហាមមិនឱ្យធ្វើការងារមួយចំនួនដែលងាយបង្ក គ្រោះថ្នាក់ ដូចជាការងារពុះអុស ការងារធ្វើដី ជ្រុំដី ការងារនៅកន្លែងម៉ាស៊ីនផលិតឥដ្ឋជាដើម ។

ចំពោះស្ត្រីមានផ្ទៃពោះចាប់ពីបីខែឡើងទៅ អាចអនុញ្ញាតឱ្យធ្វើតែការងារស្រាលៗប៉ុណ្ណោះ ។

**ប្រការ ៧.- សេវាសុខភាព**

និយោជក នៃសហគ្រាស សិប្បកម្មឡឥដ្ឋទាំងអស់ ត្រូវរៀបចំឱ្យមានសេវាសុខភាពសម្រាប់កម្មករនិយោជិតរបស់ ខ្លួន ស្របនឹងប្រកាសរួមលេខ ៣៣០ ស.ក.ប.យ ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០០០ ស្តីពីការរៀបចំគិលានដ្ឋាន សហគ្រាស និងប្រកាសរួមលេខ ១៣៩ ស.ក.ប.យ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០០១ ស្តីពីលក្ខខណ្ឌ និងបេសកកម្មសេវាពេទ្យសហគ្រាស ។

**ប្រការ ៨.-**

ការមិនអនុវត្តន៍តាមបទប្បញ្ញត្តិទាំងឡាយនៃប្រកាសនេះ ត្រូវពិន័យ ឬទទួលទោស ដូចមានចែងក្នុងជំពូកទី១៦នៃច្បាប់ ស្តីពីការងារ ។

**ប្រការ ៩.-**

ប្រកាសនេះមានប្រសិទ្ធិភាពអនុវត្ត ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**រដ្ឋមន្ត្រី**

**វង សូត**

**ចម្លងជូន :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី **សុខ អាន**
- គ្រប់ក្រសួងពាក់ព័ន្ធ **"ដើម្បីជូនជ្រាប"**
- អគ្គនាយកដ្ឋានការងារ
- អគ្គនាយកដ្ឋានកិច្ចការរដ្ឋបាល និងហិរញ្ញវត្ថុ
- គ្រប់មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្ត-ក្រុង **"ដើម្បីផ្សព្វផ្សាយ និងអនុវត្ត"**
- សមាគមនិយោជក និងសមាគមពាណិជ្ជកម្មកម្ពុជា **"ដើម្បីអនុវត្ត"**
- សហព័ន្ធសហជីព **"ដើម្បីជូនជ្រាប"**
- គ្រប់បណ្តាញវិទ្យុនិងទូរទស្សន៍ **"ដើម្បីជួយផ្សព្វផ្សាយ"**
- កាលប្បវត្តិ និងឯកសារ